# សេចក្តីថ្លែងការណ៍រួម

## មជ្ឈមណ្ឌលឃុំឃាំង និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត

*អង្គភាពអង្គការសហប្រជាជាតិសូមអំពាវនាវឲ្យរដ្ឋទាំងឡាយបិទមជ្ឈមណ្ឌលឃុំឃាំង និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត ហើយអនុវត្តន៍ដោយស្ម័គ្រចិត្តដោយមានភស្តុតាង និងព័ត៌មានទាក់ទងនឹងបញ្ហាសុខភាព និងសេវាសង្គមនៅក្នុងសហគមន៍*

ការបន្តមានអត្ថិភាពនៃមជ្ឈមណ្ឌលឃុំឃាំង និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត ជាកន្លែងដែលអ្នកដែលសង្ស័យថាប្រើប្រាស់គ្រឿងញៀន ឬញៀនគ្រឿងញៀន អ្នកដែលបំរើការខាងសេវាផ្លូវភេទ ឬកុមារដែលជាជនរងគ្រោះដោយការធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានឃុំខ្លួនដោយមិនបានអនុវត្តតាមនីតិវិធីត្រឹមត្រូវ តាមឈ្មោះជា " ការព្យាបាល" ឬ "ការស្តារនីតិសម្បទា" គឺជាកង្វល់មួយដ៏ធ្ងន់ធ្ងរ។

មជ្ឈមណ្ឌលឃុំឃាំង និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត[1] លេចឡើងជាបញ្ហាសិទ្ធិមនុស្ស និងគំរាមដល់សុខភាពអ្នកជាប់ឃុំ រាប់ទាំងតាមរយៈការបង្កើនឡើងនៃភាពងាយរងគ្រោះដល់ការឆ្លងមេរោគអេដស៍ និងជម្ងឺរបេងផងដែរ។ លក្ខណៈវិនិច្ឆ័យសម្រាប់ការឃុំខ្លួនបុគ្គលទាំងឡាយនៅក្នុងមជ្ឈមណ្ឌលទាំងនេះ មានភាពខុសគ្នានៅក្នុង និងនៅចំណោមប្រទេសផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ ការឃុំខ្លួនបែបនេះជារឿយៗកើតមាន ដោយមិនអនុវត្តទៅតាមនីតិវិធីត្រឹមត្រូវគ្រប់គ្រាន់ ការការពារផ្នែកច្បាប់ ឬការត្រួតពិនិត្យរបស់តុលាការឡើយ។ ការដកហូតសេរីភាពដោយមិនអនុវត្តទៅតាមនីតិវិធីត្រឹមត្រូវ គឺជាការរំលោភដែលមិនអាចទទួលយកបានលើបទដ្ឋានសិទ្ធិមនុស្សដែលបានទទួលស្គាល់ជាអន្តរជាតិ។ លើសពីនេះទៀត ការឃុំខ្លួននៅក្នុងមជ្ឈមណ្ឌលទាំងនេះ ត្រូវបានគេរាយការណ៍ថា ពាក់ព័ន្ធនឹងអំពើហឹង្សាលើរូប កាយ និងផ្លូវភេទ ការងារដោយបង្ខំ លក្ខខណ្ឌក្រោមកម្រិតស្តង់ដារ ការបដិសេធកិច្ចគាំពារសុខភាព និងវិធានការដទៃផ្សេងទៀតដែលរំលោភសិទ្ធិមនុស្ស។

មិនមានភស្តុតាងដែលបង្ហាញថាមជ្ឈមណ្ឌលទាំងនេះ តំណាងឲ្យបរិយាកាសអំណោយផល ឬមានប្រសិទ្ធភាពសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀន សម្រាប់ "ការស្តារនីតិសម្បទា" របស់បុគ្គលទាំងឡាយដែលបំរើការខាងសេវាផ្លូវភេទ ឬកុមារដែលជាជនរងគ្រោះដោយការធ្វើអាជីវកម្មផ្លូវភេទ ការរំលោភបំពាន ឬកង្វះការការពារ និងកិច្ចគាំពារគ្រប់គ្រាន់។

អង្គភាពអង្គការសហប្រជាជាតិ ដែលបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍នេះ[2] អំពាវនាវដល់រដ្ឋទាំងឡាយ

[1] លក្ខខណ្ឌជាច្រើន ត្រូវបានប្រើប្រាស់សម្រាប់មជ្ឈមណ្ឌលទាំងនេះ។

[2] អង្គការពលកម្មអន្តរជាតិ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ អង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌ អ.ស.ប មូលនិធិប្រជាជនអង្គការសហប្រជាជាតិ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ ការិយាល័យ

ដែលប្រតិបត្តិការមជ្ឈមណ្ឌលឃុំឃាំង និងស្ថានីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត បិទមជ្ឈមណ្ឌលទាំងនោះ ដោយគ្មានការពន្យារពេល និងដោះលែងបុគ្គលទាំងឡាយដែលជាប់ឃុំឲ្យមានសេរីភាពវិញ។ ក្រោយពីដោះលែងឲ្យមានសេរីភាពវិញ គួរតែផ្តល់សេវាគាំពារសុខភាពសមរម្យដល់អ្នកដែលត្រូវការសេវាបែបនេះ តាមគោលការណ៍ស្ម័គ្រចិត្ត នៅកម្រិតសហគមន៍។ សេវាទាំងនេះ គួរតែរួមបញ្ចូលការព្យាបាលអ្នកដែលគេដឹងច្បាស់ថាពិតជាញៀនគ្រឿងញៀន ការបង្ការ ការពិនិត្យព្យាបាល កិច្ចគាំពារ និងការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និងអ្នកមានជម្ងឺរបេង ក៏ដូចជាសេវាសុខាភិបាល សេវាច្បាប់ និងសេវាសង្គម ដើម្បីដោះស្រាយអំពើហិង្សាផ្លូវកាយ និងផ្លូវភេទ និងផ្តល់លទ្ធភាព ធ្វើសមាហរណកម្ម។ អង្គការសហប្រជាជាតិត្រៀមខ្លួនជាស្រេច ដើម្បីធ្វើការជាមួយរដ្ឋទាំងឡាយ នៅពេលដែលរដ្ឋចាត់វិធានការបិទមជ្ឈមណ្ឌលឃុំឃាំង និងស្ថានីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត និងដើម្បីអនុវត្តជម្មើសជំនួសដោយស្ម័គ្រចិត្ត នៅតាមលំនៅដ្ឋាន និងមានភស្តុតាងច្បាស់ អាចដំណើរការបាននៅក្នុងសហគមន៍។

ប្រសិនជារដ្ឋណាមួយមិនអាចបិទមជ្ឈមណ្ឌលបានឆាប់រហ័ស ដោយមិនត្រូវអូសបន្លាយពេលហួសហេតុ យើងសូមអំពាវនាវឲ្យបង្កើតជាបន្ទាន់ដូចតទៅ៖

- ដំណើរការមួយ ដើម្បីពិនិត្យឡើងវិញនូវការឃុំខ្លួនអ្នកទាំងឡាយដែលស្ថិតនៅក្នុងមជ្ឈមណ្ឌល ដើម្បីធានាថាមិនមានការឃុំខ្លួនដោយបំពាន ហើយថាការឃុំខ្លួនត្រូវបានធ្វើឡើងស្របតាមបទដ្ឋានអន្តរជាតិស្តីពីនីតិវិធីត្រឹមត្រូវ និងផ្តល់ជម្រើសជំនួសឲ្យការដាក់ពន្ធនាគារ។ ការពិនិតឡើងវិញនេះ នឹងអនុញ្ញាតឲ្យមានការកំណត់អត្តសញ្ញាណអ្នកដែលគួរតែត្រូវបានដោះលែងជាបន្ទាន់ និងអ្នកដែលគួរតែត្រូវបានបញ្ជូនសម្រាប់កម្មវិធីព្យាបាលដោយស្ម័គ្រចិត្តដែលមានភស្តុតាងច្បាស់លាស់នៅក្នុងសហគមន៍។
- ដំណើរការមួយ ដើម្បីពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃការឃុំខ្លួន និងមជ្ឈមណ្ឌលស្ថានីតិសម្បទាអ្នកញៀនគ្រឿងជាញៀនជាកំហិត សំដៅកែលម្អស្ថានភាពទាំងនោះឲ្យបានឆាប់រហ័ស ដើម្បីបំពេញតាមបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ ដែលអាចអនុវត្តនៅក្នុងគ្រឹះស្ថានបិទទ្វារ រាប់ទាំងការទទួលបានសេវាគាំពារសុខភាពដែលមានគុណភាព និងព័ត៌មានភស្តុតាងសេវាសង្គម និងការអប់រំ និងលុបបំបាត់ការប្រព្រឹត្តអមនុស្សធម៌ ឬបន្ថោកបន្ទាប និងការងារដោយបង្ខំ[3] រហូតដល់មជ្ឈមណ្ឌលត្រូវបានបិទ។
- ការផ្តល់សេវាគាំពារសុខភាព ខណៈពេលកំពុងរង់ចាំការបិទមជ្ឈមណ្ឌល រាប់ទាំងការព្យាបាលមេរោគអេដស៍/ជម្ងឺអេដស៍ និងជម្ងឺកាមរោគ ជម្ងឺរបេង និងជម្ងឺឱកាសនិយម ក៏ដូចជាសេវាសុខភាព និងសេវាច្បាប់ ដើម្បីឆ្លើយតបនឹងអំពើហិង្សាផ្លូវកាយនិងផ្លូវភេទ។

• ការត្រួតពិនិត្យដោយតុលាការ និងការត្រួតពិនិត្យដោយឯករាជ្យដទៃផ្សេងទៀត ហើយរាយការណ៍អំពីការពិនិត្យឡើងវិញ និងដំណើរការបិទមជ្ឈមណ្ឌល និងការផ្អាកការទទួលឲ្យចូលចូលបន្ថែមទៀត ទៅក្នុងមណ្ឌលឃុំខ្លួន និងស្ថានីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត របស់អ្នកដែលប្រើប្រាស់គ្រឿងញៀន អ្នកដែលបម្រើការងារខាងសេវាផ្លូវភេទ និងកុមារជនរងគ្រោះដោយការធ្វើអាជីវកម្មផ្លូវភេទ។

ភស្តុតាងបង្ហាញថា ការឆ្លើយតបដែលមានប្រសិទ្ធភាពបំផុតចំពោះការពឹងផ្អែកលើគ្រឿងញៀននិងគ្រោះថ្នាក់ដែលទាក់ទងនឹងសុខភាពដែលទាក់ទងនឹងវាដូចជាការឆ្លងមេរោគអេដស៍តម្រូវឱ្យមានការព្យាបាលការពឹងអាស្រ័យលើថ្នាំញៀន។ ស្ថានភាពសុខភាពតាមរយៈវិធីសាស្ត្រដែលមានមូលដ្ឋានលើភស្តុតាងនិងផ្អែកលើសិទ្ធិដែលក្នុងករណីជាច្រើនចាំបាច់ត្រូវបង្កើតឡើង។ អន្តរាគមន៍ថែទាំសុខភាពទាំងអស់រួមទាំងការព្យាបាលដោយពឹងផ្អែកលើគ្រឿងញៀនគួរតែត្រូវបានអនុវត្តដោយស្ម័គ្រចិត្ត

---

អង្គការសហប្រជាជាតិសម្រាប់គ្រឿងញៀន និងឧក្រិដ្ឋកម្ម អង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី កម្មវិធីស្បៀងអាហារពិភពលោក អង្គការសុខភាពពិភពលោក និងកម្មវិធីរួមរបស់អង្គការសហប្រជាជាតិស្តីពីជម្ងឺអេដស៍។

[3]សម្រាប់ព័ត៌មានបន្ថែម អំពីវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស ចំពោះមេរោគអេដស៍/ជម្ងឺអេដស៍ នៅក្នុងបរិបទការងារ សូមមើលអនុសាសន៍របស់អង្គការ ILO ស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍ និងពិភពលោកនៃការងារ ឆ្នាំ២០១០ (លេខ ២០០) ។

ដោយមានការយល់ព្រមពីព័ត៌មានលើកលែងតែក្នុងករណីពិសេសដែលបានកំណត់យ៉ាងច្បាស់លាស់ស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលធានាថាបទប្បញ្ញត្តិទាំងនោះមិនត្រូវបានរំលោភបំពាន។ ការឆ្លើយតបទៅនឹងការប្រើគ្រឿងញៀននិងគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងសុខភាពគួរតែរួមបញ្ចូលការបង្ការនិងការព្យាបាលអេដស៍ជំងឺអេដស៏ជំងឺកាមរោគនិងជំងឺរបេងផ្សេងៗទៀតសម្រាប់អ្នកដែលប្រើប្រាស់គ្រឿងញៀន។

ប្រសិនជាអ្នកបម្រើការងារខាងសេវាផ្លូវភេទទទួលបានអត្ថប្រយោជន៍ពីនីតិវិធីត្រឹមត្រូវនេះ ការការពារពីការរើសអើង និងអំពើហឹង្សា និងលទ្ធភាពទទួលបានការបង្ការ ការព្យាបាល កិច្ចគាំពារ និងការគាំទ្រ ខាងមេរោគអេដស៍/ជម្ងឺអេដស៍ ពួកគេអាចកាត់បន្ថយភាពងាយរងគ្រោះយ៉ាងច្រើន និងចំពោះអតិថិជនរបស់ពួកគេពីចំពោះមេរោគអេដស៍/ជម្ងឺអេដស៍ និងជម្ងឺកាមរោគដទៃទៀត។

ក្នុងករណីដែលកុមារអាយុក្រោម ១៨ ឆ្នាំ ការឆ្លើយតបសមស្របនិងមានប្រសិទ្ធភាពបំផុត គឺគ្រួសារជាមូលដ្ឋាន និងកសាងបន្ថែមលើកម្លាំងរបស់សហគមន៍មូលដ្ឋាន។[4] ទាំងនេះគួរតែជាជម្រើសទីមួយ ក្នុងការគោរពពេញលេញចំពោះសិទ្ធិរបស់ពួកគេខាងសុខុមាលភាព ការការពារ ការគាំពារ និងយុត្តិធម៌។ កុមារដែលបំរើការ ឬបានបំរើការក្នុងការងារផ្លូវភេទ គួរតែត្រូវបានចាត់ទុកថាជាកុមារដែលរួចចាកផុតពីការធ្វើអាជីវកម្មផ្លូវភេទ ដោយអនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩) និងអនុសញ្ញាលេខ១៨២ របស់អង្គការពលកម្មអន្តរជាតិ ស្តីពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ឆ្នាំ១៩៩៩ មិនត្រូវចាត់ទុកជាជនល្មើសដែលត្រូវទទួលទោសព្រហ្មទណ្ឌឡើយ។ កុមារទាំងនោះ ដែលញៀនគ្រឿងញៀន គួរតែទទួលបានអត្ថប្រយោជន៍ពីកម្មវិធីដែលផ្អែកលើសិទ្ធិ និងភស្តុតាង ដើម្បីជួយសម្រួលដល់ការស្តារសម្បទា និងការធ្វើសមាហរណកម្មពួកគេទៅក្នុងគ្រួសារ និងសហគមន៍។

រដ្ឋទាំងឡាយកាន់តែទទួលស្គាល់ច្រើនឡើងៗនូវកង្វល់អំពីមជ្ឈមណ្ឌលឃុំខ្លួន និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត រាប់ទាំងការខ្វះប្រសិទ្ធភាពក្នុងការបង្ការការលាប់ ការចំណាយខ្ពស់ និងផលប៉ះពាល់អវិជ្ជមានដែលអាចមានរបស់ពួកគេលើកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាការទទួលបានការបង្ការ ការព្យាបាល កិច្ចគាំពារ និងការគាំទ្រ ខាងមេរោគអេដស៍/ជម្ងឺអេដស៍។ យើងកត់សម្គាល់ដោយការវាយតម្លៃខ្ពស់ថាប្រទេសមួយចំនួន បាននិងកំពុងដំណើរការកាត់បន្ថយចំនួនមជ្ឈមណ្ឌលដូចនេះ និងការកសាងសមត្ថភាពកាន់តែច្រើនថែមទៀត សម្រាប់វិធីសាស្រ្តតាមគោលការណ៍ស្ម័គ្រចិត្ត ផ្អែកលើភស្តុតាង និងនៅតាមសហគមន៍។ ជំហានវិជ្ជមានទាំងនេះមានសារៈសំខាន់ណាស់ ក្នុងការពង្រីកការយល់ដឹង និងការគាំទ្រដល់វិធីសាស្រ្តចំពោះសារធាតុញៀន ការងារផ្លូវភេទ និងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ដែលផ្អែកលើភស្តុតាងបែបវិទ្យាសាស្រ្ត និងវេជ្ជសាស្រ្តដែលអាចរកបាន ដើម្បីធានាការពារសិទ្ធិមនុស្ស និងលើកកម្ពស់សុខភាពសាធារណៈ។

យើងសន្យាធ្វើការជាមួយបណ្តាប្រទេសនានា ដើម្បីស្វែងរកមធ្យោបាយជំនួសមជ្ឈមណ្ឌលឃុំខ្លួន និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនជាកំហិត រាប់ទាំងតាមរយៈការជួយឧបត្ថម្ភផ្នែកបច្ចេកទេស ការកសាងសមត្ថភាព និងការតស៊ូមតិ។ ទម្រង់នៃការគាំទ្រ អាចមានដូចខាងក្រោម៖

- ការចែករំលែកព័ត៌មាន និងការអនុវត្តល្អ ស្តីពីកម្មវិធីស្ម័គ្រចិត្ត ផ្អែកលើសិទ្ធិ ព័ត៌មានភស្តុតាង និងសហគមន៍ សម្រាប់អ្នកដែលប្រើប្រាស់គ្រឿងញៀន អ្នកបម្រើការងារខាងផ្លូវភេទ និងកុមាររងគ្រោះដោយការធ្វើអាជីវកម្មផ្លូវភេទ។

- កិច្ចសន្ទនាជាមួយអ្នកតាក់តែងគោលនយោបាយ ដើម្បីបង្កើនការគាំទ្រដល់កម្មវិធីស្ម័គ្រចិត្ត ផ្អែកលើសិទ្ធិ ព័ត៌មានភស្តុតាង និងសហគមន៍ សម្រាប់អ្នកញៀនគ្រឿងញៀន។

- កិច្ចសហប្រតិបត្តិការពហុវិស័យក្នុងចំណោមស្ថាប័នអនុវត្តច្បាប់សុខាភិបាលប្រព័ន្ធតុលាការសិទ្ធិមនុស្សសុខុមាលភាពសង្គមនិងស្ថាប័នគ្រប់គ្រងគ្រឿងញៀនជួយក្នុងការបង្កើតក្របខ័ណ្ឌសកម្មភាពដើម្បីគាំទ្រដល់សេវាកម្មស្ម័គ្រចិត្តនិងសហគមន៍សម្រាប់អ្នកដែលប្រើប្រាស់ថ្នាំញៀនអ្នកដែលរួមភេទនិងកុមារដែល ត្រូវបានជនរងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទ។ និង

- ការបង្កើតសវាផ្សេងៗ ដើម្បីដោះស្រាយមូលហេតុដែលជាឫសគល់នៃភាពងាយរងគ្រោះ (ឧទា. ភាពក្រីក្រ វិសមភាពយេនឌ័រ និងកង្វះរចនាសម្ព័ន្ធគ្រប់គ្រាប់ ដើម្បីគាំទ្រគ្រួសារ និងសហគមន៍) ។

*ខែមីនា ឆ្នាំ២០១២*

[4] សូមមើលផងដែរឯកសាររបស់អង្គការយូនីសេហ្វដែលមានចំណងជើងថា "ជំហស្តីពីមជ្ឈមណ្ឌលឃុំខ្លួនជាកំហិត នៅអាស៊ីបូព៌ានិងប៉ាស៊ីហ្វិក"។ អាចរកបានលើវេបសាយ http://www.unicef.org/eapro/ media_18366.html។